UNITED NATIONS
HUMAN RIGHTS COUNCIL

MEDIA ADVISORY

# កំណត់ត្រាសិទ្ធិមនុស្សរបស់កម្ពុជានឹងត្រូវពិនិត្យដោយយន្តការពិនិត្យឡើងវិញ ជាសកលតាមកាលកំណត់

**ទីក្រុងហ្សឺណែវ ( ៣ ឧសភា ២០២៤)** - កំណត់ត្រាសិទ្ធិមនុស្សរបស់កម្ពុជានឹងត្រូវពិនិត្យដោយក្រុមការងារ ការពិនិត្យឡើងវិញ ជាសកលតាមកាលកំណត់ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ជាលើកទីបួន នៅថ្ងៃពុធ ទី៨ ខែឧសភា ឆ្នាំ២០២៤ នៅក្នុងកិច្ចប្រជុំនៅទីក្រុងហ្សឺណែវ ដែលនឹងចាក់ផ្សាយផ្ទាល់តាមប្រព័ន្ធវេបខាស់។

កម្ពុជា គឺជារដ្ឋមួយក្នុងចំណោមរដ្ឋចំនួន១៤ នឹងត្រូវបានពិនិត្យដោយក្រុមការងារ UPR របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងសម័យប្រជុំមួយដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤។ ការពិនិត្យឡើងវិញជាសាកលតាមកាលកំណត់ លើកទី១ លើកទី២ និងលើកទី៣ របស់កម្ពុជា ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ក្នុងខែធ្នូ ឆ្នាំ២០០៩ ខែមករា ឆ្នាំ២០១៣ និងខែមករា ឆ្នាំ២០១៩។

ក្រុមការងារ UPR មានសមាសភាព ចំនួន៤៧រដ្ឋ គឺជារដ្ឋសមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ យ៉ាងណាក្តី រាល់រដ្ឋសមាជិកទាំង ១៩៣ នៃអង្គការសហប្រជាជាតិអាចចូលរួមក្នុងការពិនិត្យរបស់ប្រទេសមួយទៀតបាន។

ការពិនិត្យនេះ ផ្អែកលើឯកសារ៖ ១) របាយការណ៍ជាតិ - ព័ត៌មានដែលផ្តល់ឱ្យដោយរដ្ឋស្ថិតក្រោមការពិនិត្យ ២) ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញ និងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យ ដែលគេស្គាល់ថា ជានីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងអង្គភាពដទៃទៀតរបស់អង្គការសហប្រជាជាតិ ៣) ព័ត៌មាន ដែលផ្តល់ដោយភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងស្ថាប័នជាតិសិទ្ធិមនុស្ស អង្គការតំបន់ និងក្រុមសង្គមស៊ីវិល។

**របាយការណ៍**ទាំងបីនេះ ត្រូវបានប្រើជាមូលដ្ឋានសម្រាប់ការពិនិត្យសំរាប់កម្ពុជានៅថ្ងៃទី៨ ខែឧសភា ដែលអាចរកបាននៅទីនេះ។

**ទីកន្លែង៖** បន្ទប់លេខ២០ Palais des Nations ទីក្រុងហ្សឺណែវ

**ម៉ោងនិងកាលបរិច្ឆេទ៖** ១៤:០០ ដល់ម៉ោង ១៧:៣០ ថ្ងៃពុធ ទី៨ ខែឧសភា ឆ្នាំ២០២៤ (ម៉ោងនៅរាជធានីភ្នំពេញ)

UPR គឺជាដំណើរការពិនិត្យរវាងរដ្ឋ និងរដ្ឋ លើកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកអង្គការសហប្រជាជាតិទាំង ១៩៣រដ្ឋ។ ចាប់តាំងពីកិច្ចប្រជុំលើកទី១ របស់ខ្លួន ត្រូវបានប្រារព្ធឡើង នៅ ខែមេសា ឆ្នាំ២០០៨ មក រដ្ឋទាំង១៩៣ របស់អង្គការសហប្រជាជាតិ ត្រូវបានពិនិត្យបីដងរួចមកហើយ។

នៅក្នុងអំឡុងពេលជុំទី៤ នៃ UPR នេះ រដ្ឋទាំងឡាយ ត្រូវបានគេរំពឹងម្តងទៀតថា នឹងបង្ហាញប្រាប់ពីវិធានការផ្សេងៗ ដែលរដ្ឋខ្លួនបានចាត់ឡើង ដើម្បីអនុវត្តអនុសាសន៍ទាំងឡាយដែលត្រូវបានផ្តល់ដោយរដ្ឋសមាជិកដទៃ នៅក្នុងអំឡុងពេលនៃការពិនិត្យលើកមុន ដែលរដ្ឋក្រោមការពិនិត្យបាន ប្តេជ្ញាអនុវត្តតាម ហើយក៏ដូចជា ដើម្បីគូសបញ្ជាក់ពី វឌ្ឍនភាពសិទ្ធិមនុស្សថ្មីៗ នៅក្នុងប្រទេសរបស់ ខ្លួន។

ឯកឧត្តម កែវ សុទ្ធិ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នឹងដឹកនាំគណៈប្រតិភូកម្ពុជា។

តំណាងប្រទេសចំនួនបី ដែលធ្វើជាអ្នករាយការណ៍ ("ត្រយកា") សម្រាប់ការពិនិត្យរបស់កម្ពុជា គឺប្រទេសហ្កាណា ប្រទេសជប៉ុន និងប្រទេសម៉ុងតេណេហ្គ្រូ។

**វេបខាស់**នៃសម័យប្រជុំនេះ នឹងមាននៅលើគេហទំព័រ ៖https://webtv.un.org/en/asset/k1m/k1myt1y4lw

បញ្ជីឈ្មោះវាគ្មិន និងសេចក្តីថ្លែងការណ៍ដែលមានទាំងអស់ ដែលត្រូវថ្លែងនៅក្នុងអំឡុងការពិនិត្យរបស់កម្ពុជានឹងត្រូវដាក់បង្ហោះនៅលើ UPR Extranet ។

ក្រុមការងារ UPR **គ្រោងនឹងអនុម័តអនុសាសន៍នានា** ដែលបានផ្តល់ជូនទៅកម្ពុជានៅចន្លោះម៉ោង១៦.០០ ទៅដល់ម៉ោង១៨.០០ (ម៉ោងនៅអឺរ៉ុបកណ្តាល) នៃថ្ងៃសុក្រ ទី១០ ខែឧសភា ឆ្នាំ២០២៤។ រដ្ឋដែលស្ថិតក្រោមការពិនិត្យ អាចបង្ហាញពីជំហររបស់ខ្លួនចំពោះអនុសាសន៍ដែលទទួលបានក្នុងអំឡុងការពិនិត្យនេះ។

**ចប់**

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទង ៖ **លោក ប៉ាស្កាល់ ស៊ីម មន្ត្រីប្រព័ន្ធផ្សព្វផ្សាយនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** តាមរយៈអាស័យដ្ឋានសារអេឡិចត្រូនិច **simp@un.org** ឬ **លោកម៉ាទូ ប្រោន មន្ត្រីពត៌មានសាធារណៈនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** តាមរយៈអាស័យដ្ឋានសារអេឡិចត្រូនិច **matthew.brown@un.org** ឬក៏ លោក ដេវីត ដាយេស ម៉ាទីន **មន្ត្រីពត៌មានសាធារណៈនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ**តាមរយៈអាស័យដ្ឋានសារអេឡិចត្រូនិច **david.diazmartin@un.org***

*ដើម្បីស្វែងយល់បន្ថែមអំពីយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ សូមចូលទៅកាន់៖* **www.ohchr.org/en/hr-bodies/upr/upr-main**

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប សូមស្វែងយល់ពីយើងតាមរយៈបណ្តាញសង្គម៖**
**Facebook** | **Twitter** | **YouTube** | **Instagram**